**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រៃវែង**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៧៧

ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

**សាលក្រមព្រហ្មទណ្ឌ**

**លេខ៖ ៨២/១៤ "ខ"**

ចុះថ្ងៃទី០២ ខែមីនា គ.ស.២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តព្រៃវែង**

បានបើកសវនាការជាសាធារណ:នៅសាលជម្រះក្តីនៃសាលាដំបូងខេត្តព្រៃវែង នាថ្ងៃទី០៨ ខែកុម្ភៈ គ.ស.២០២៣ វេលាព្រឹក ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ឋាន:ចៅក្រម

**តំណាងអយ្យការ**

-លោក [redacted] ឋាន:ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ឋាន:ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៧៧ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចិត្រ ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើត និងទីលំនៅបច្ចុបន្នភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] ធឿន (រស់) ម្តាយឈ្មោះ [redacted] រីម (រស់) ពោះម៉ាយ មានកូនចំនួន១នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន។ (សាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តីលេខ៖ ១៩/០៤ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២)

ជាប់ចោទពីបទ៖ ហិង្សាដោយចេតនា តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រីម ភេទស្រី អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង។

-ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះឈ្មោះ [redacted] គីមហៀប ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរអ្នកសារព័ត៌មាន មានទីលំនៅបច្ចុប្បន្នភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

-បានឃើញដីកាដំណោះស្រាយលេខ៖ ៣២០២ ដស.ព្រទ/២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រៃវែង។

-បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ៤៥១/២០២២ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រៃវែង។

**អង្គហេតុ**

កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៣០នាទី ឈ្មោះ [redacted] ចិត្រ ស្រវឹងស្រា ហើយជិះម៉ូតូរោទ៍សំឡេងខ្លាំងៗ នៅចំណុចមុខផ្ទះរបស់ឈ្មោះ [redacted] គីមហៀប ស្ថិតនៅភូមិល្វាកោង ពេលនោះ



Scanned with CamScanner

ឈ្មោះ [redacted] គីមហៀប បានដើរចេញទៅមើល ហើយក៏មានការឈ្លោះប្រកែកគ្នា កើតជារឿងប្រតាយប្រតប់គ្នាទៅវិញទៅមក បណ្តាលឱ្យឈ្មោះ [redacted] ចិត្រ ដួលទៅប៉ះទ្វារដែករងរបួសដាច់ស្បែកថ្ងាសលើចិញ្ចើម រីឯឈ្មោះ [redacted] គីមហៀប ដួលទៅលើដីរងរបួសដាច់រលាត់ស្បែកក្បាលជង្គង់ឆ្វេង។ ក្រោយមកបងប្អូនជិតខាងនៅទីនោះបានជួយចាប់ឃាត់បំបែកគ្នាចេញរៀងៗខ្លួន។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ចិត្រ បានឆ្លើយថា ខ្លួនទទួលស្គាល់បទចោទប្រកាន់។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ខ្លួនបានទៅផឹកស្រានៅផ្ទះរបស់ឈ្មោះ [redacted] យឹម ផឹករហូតដល់ម៉ោងប្រហែល១៨ និង៣០នាទី ខ្លួនបានចេញពីកន្លែងផឹកត្រឡប់មកដល់ផ្ទះវិញ ដោយជិះពីទិសខាងជើងមកទិសខាងត្បូង រួចខ្លួនបានរោទិ៍ម៉ូតូបង្កឱ្យមានសំឡេងខ្លាំងដោយសារពេលនៅកន្លែងផឹកម៉ូតូធ្វើទុករអាក់រអួល និងជិតអស់សាំង។ ពេលដែលខ្លួនរោទិ៍ម៉ូតូលឺសំឡេងខ្លាំងៗនោះគឺនៅលើផ្លូវចំហៀងផ្ទះរបស់ឈ្មោះ [redacted] គីមហៀប។ ពេលនោះស្រាប់តែឈ្មោះ ហៀប ហៅខ្លួន រួចក៏ឈ្លោះប្រកែកគ្នាដោយពាក្យសម្តី និងវាយប្រតាយប្រតប់គ្នាទៅវិញទៅមក ហើយឈ្មោះ ហៀប បានចាប់សក់ក្បាលខ្លួនបោកទៅនឹងផ្លូវថ្មខាងមុខផ្ទះរបស់ឈ្មោះ [redacted] គីមហៀប។ ក្នុងពេលដែលខ្លួនប្រតាយប្រតប់ជាមួយឈ្មោះ [redacted] គីមហៀប មានរយៈពេលប្រហែលជា២នាទី ហើយក៏មានបងប្អូនជិតខាងចូលទៅឃាត់។ ក្រោយពីមានជម្លោះរួចមក ខ្លួនក៏បានចេញទៅធ្វើការងារជាកម្មករសំណង់នៅភ្នំពេញ ដោយខ្លួនមិនដែលបានទទួលដីកាកោះហៅរបស់តុលាការនោះទេ ហើយខ្លួនក៏មិនដែលមានគំនុំជាមួយឈ្មោះ [redacted] គីមហៀប ដែរ។ ខ្លួនពុំបានកាច់របងបង្គោលដើម្បីយកទៅវាយឈ្មោះ [redacted] គីមហៀប នោះទេ ប៉ុន្តែខ្លួនបានដើរឆ្លងផ្លូវទៅរកវាយឈ្មោះ [redacted] គីមហៀប ប្រាកដមែន។

-ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះឈ្មោះ [redacted] គីមហៀប បានឆ្លើយថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៣០នាទី ខ្លួនកំពុងនិយាយគ្នាជាមួយឈ្មោះ ហេង និងឈ្មោះ បូរ៉ា នៅខាងក្រោយផ្ទះក្បែរមាត់ទន្លេ ក៏បានលឺសូរសំឡេងម៉ូតូរោទិ៍ខ្លាំងៗ និងលឺសូរឈ្មោះ [redacted] ចិត្រ ជេរប្រមាថមកលើខ្លួន ហើយខ្លួនក៏បានដើរចេញមកខាងមុខផ្ទះឃើញឈ្មោះ [redacted] ចិត្រ និងបានសួរនាំទៅជននេះ ស្រាប់តែឈ្មោះ [redacted] ចិត្រ រត់ទៅកាច់របងបង្គោល និងបោកក្បាលនឹងរបង ហើយក៏រត់មកវាយលើខ្លួនបណ្តាលឱ្យខ្លួនរងរបួសជាច្រើន ហើយខ្លួនដួលលុតជង្គង់លើគ្រួសថ្មតែម្តង។ នៅពេលប្រតាយប្រតប់គ្នានោះគឺឪពុករបស់ឈ្មោះ [redacted] ចិត្រ និងឈ្មោះ ចាន់ បានវាយឱ្យខ្លួនដួល ហើយខ្លួនមិនបានធ្វើសកម្មភាពទៅលើជនជាប់ចោទទេ។ ខ្លួនស្គាល់ជនជាប់ចោទ និងមិនដែលមានទំនាស់នោះទេ ប៉ុន្តែជនជាប់ចោទខឹងនឹងខ្លួនដែលបានចុះផ្សាយរឿងបងប្អូនពាក់ព័ន្ធនឹងគ្រឿងញៀន។ របួសក្បាលជង្គង់មានលក្ខណៈស្រាល ហើយខ្លួនបានលេបថ្នាំអស់រយៈពេល១អាទិត្យ និងចំណាយប្រាក់អស់៥០ដុល្លារអាមេរិក ប៉ុន្តែពុំមានវិក្កយបត្របញ្ជាក់ការចំណាយនោះទេ។ ខ្លួនសូមទាមទារសំណងចំនួន ៣០,០០០ដុល្លារអាមេរិកពីជនជាប់ចោទដោយសារតែខ្លួនបានចំណាយប្រាក់សម្រាប់ការព្យាបាល និងបាត់បង់កត្តិយស។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រីម ជាម្តាយរបស់ជនជាប់ចោទបានឆ្លើយថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៤០នាទី នៅមុនពេលកើតហេតុខ្លួនបាននៅខាងក្រោយផ្ទះ

ហើយក្រោយមកខ្លួនបានលឺសំឡេងម៉ូតូរោទិ៍ខ្លាំងៗគឺជាសំឡេងម៉ូតូរបស់កូនខ្លួន ខ្លួនក៏បានមកមុខផ្ទះឃើញកូនខ្លួនឈ្មោះ [redacted] ចិត្រ បានរោទិ៍ម៉ូតូនៅផ្ទះ។ ពេលនោះ ក៏ស្រាប់តែឈ្មោះ ហៀប ហៅកូនខ្លួនចូលទៅក្នុងផ្ទះដោយបានទាញដៃជាន់ក្បាលទៅនឹងផ្លូវដែលមានថ្មបណ្តាលឱ្យមានរបួសថ្ងាសហូរឈាម ហើយខ្លួន និងប្តីបានទាញដៃកូនចូលមកផ្ទះវិញ។ ក្បាលរបស់កូនខ្លួនបែកព្យាបាលអស់រយៈពេល៦ថ្ងៃ នៅភ្នំពេញ ដោយចំណាយអស់ប្រាក់១០,០០០ដុល្លារអាមេរិក ប៉ុន្តែគ្មានវិក្កយបត្រចំណាយទេ។ ខ្លួនសូមទាមទារសំណងថ្លៃព្យាបាលចំនួន៤០,០០០ដុល្លារអាមេរិកពីឈ្មោះ [redacted] គឹមហៀប។

-សាក្សីឈ្មោះ [redacted] ធឿន នៅថ្ងៃកើតហេតុខ្លួនបាននៅអង្គុយក្បែរផ្លូវកន្លែងកើតហេតុ ពេលនោះឈ្មោះ ហៀប បានហៅកូនរបស់ខ្លួនទាញដៃ និងចាប់ក្បាលជាន់ទៅនឹងផ្លូវដែលមានថ្ម បណ្តាលឱ្យថ្ងាសរបស់កូនខ្លួនបែកហូរឈាម ហើយខ្លួន និងប្រពន្ធក៏បានទាញដៃកូនត្រឡប់មកផ្ទះវិញ និងមិនបានវាយឈ្មោះ ហៀប ទេ។

-សាក្សីឈ្មោះ [redacted] អៀន ជាជីដូនរបស់ជនជាប់ចោទបានឆ្លើយថា នៅពេលកើតហេតុខ្លួននៅមុខផ្ទះហើយឃើញឈ្មោះ ហៀប បានបក់ដៃហៅចៅរបស់ខ្លួនឈ្មោះ ចិត្រ ឱ្យចូល រួចឈ្មោះ ហៀប បានចាប់ដៃចៅរបស់ខ្លួន និងយកក្បាលបោកផ្តួលជាន់ក្បាលទៅនឹងផ្លូវបណ្តាលឱ្យចៅរបស់ខ្លួនរបួសបែកថ្ងាស ដោយនៅពេលនោះគឺឈ្មោះ ហៀប និងប្រពន្ធរបស់ឈ្មោះ ហៀប បានជាន់ក្បាលចៅរបស់ខ្លួនទាំងពីរនាក់តែម្តង។

-សាក្សីឈ្មោះ [redacted] ធារ៉ា បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនបានអង្គុយផឹក និងជជែកគ្នានៅខាងក្រោយផ្ទះរបស់ឈ្មោះ [redacted] គឹមហៀប ហើយក៏បានលឺគេជេរមកលើឈ្មោះ ហៀប ហើយឈ្មោះ ហៀប ក៏បានដើរទៅមុខផ្ទះដោយខ្លួនបានដើរតាមពីខាងក្រោយ។ ពេលទៅដល់មុខផ្ទះ ឈ្មោះ ចិត្រ បានហៅឈ្មោះ ហៀប វាយគ្នា។ គ្រាន់តែឈ្មោះ ហៀប ដើរចេញពីមាត់ទ្វារភ្លាម ឈ្មោះ ចិត្រ បានវាយឈ្មោះ ហៀប ត្រូវផ្ទៃមុខ១ដៃ ស្មា១ដៃ បណ្តាលឱ្យឈ្មោះ ហៀប ដួលអុកគូទ បង្កឱ្យឈ្មោះ ហៀប រងរបួសក្បាលជង្គង់។ ពេលនោះខ្លួនបានចូលទៅជួយចាប់បំបែកជាមួយនឹងឈ្មោះ ហេង ឈ្មោះ ចាន់ និងឪពុកម្តាយរបស់ឈ្មោះ ចិត្រ។ ឈ្មោះ ហៀប បានវាយទៅលើឈ្មោះ ចិត្រ ដើម្បីការពារខ្លួនតែប៉ុណ្ណោះ។

-ឈ្មោះ [redacted] ចាន់ហេង បានឆ្លើយថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៤០នាទី ពេលខ្លួនកំពុងអង្គុយនិយាយគ្នាជាមួយឈ្មោះ ហៀប និងឈ្មោះ ធារ៉ា នៅខាងក្រោយផ្ទះរឿងទិញម៉ូតូ ដោយខ្លួនបានហូតទឹកតែ រួចក៏ឮសំឡេងម៉ូតូរោទិ៍នៅខាងមុខផ្ទះ។ ពេលនោះឈ្មោះ ហៀប និងឈ្មោះ ធារ៉ា បានដើរចេញមកខាងមុខផ្ទះ ប៉ុន្តែខ្លួននៅអង្គុយនៅទីនោះដដែល ហើយក៏បានលឺសូរផ្ទុងផាំង ដែលជាសូរទង្គិចនឹងទ្វារផ្ទះ រួចក៏មានក្មេងមកប្រាប់ខ្លួនថាឈ្មោះ ហៀប បានវាយគ្នា។ ខ្លួនក៏បានទៅមើល និងបំបែកគ្នា ហើយឈ្មោះ ហៀប ពិតជាមានរបួសមែន។

**ក្រឡាបញ្ជីអានឯកសារមួយចំនួនដូចខាងក្រោម៖**

-ឈ្មោះ [redacted] ចាន់ និងឈ្មោះ [redacted] ស្រីម បានឆ្លើយប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៣០នាទី បងរបស់ខ្លួនឈ្មោះ [redacted] ចិត្រ បានធ្វើដំណើរពីជើងមកត្បូងចូលមកក្នុងផ្ទះ ហើយបានរោទិ៍ម៉ូតូឮខ្លាំងៗ។ បន្ទាប់មក បងរបស់ខ្លួនបានដើរចេញមកផ្លូវ រួចក៏ឈ្លោះប្រកែកគ្នាជាមួយឈ្មោះ [redacted] គឹមហៀប។ ក្នុងពេលនោះឈ្មោះ [redacted] គឹមហៀប បានដើរទៅចាប់បោចសក់ក្បាលបងរបស់

ខ្លួនបោកទៅនឹងទ្វារដែក ហើយខ្លួនក៏បានរត់ទៅបំបែកចេញ។

-អំណានឯកសារនានាដែលពាក់ព័ន្ធក្នុងសំណុំរឿង។

**សិទ្ធិនិយាយស្តីរបស់គាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

-មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនគឺជាជនរងគ្រោះនៃអំពើល្មើសខាងលើពិតប្រាកដមែនព្រោះជនជាប់ចោទឈ្មោះ [redacted] ចិត្រ ពិតជាបានរត់ឆ្លងផ្លូវមកវាយកូនក្តីខ្លួននៅមាត់ទ្វារផ្ទះ ដូចបញ្ជាក់នៅក្នុងវីដេអូរូបសព្ទដៃ និងកាមេរ៉ាសុវត្ថិភាពពិតប្រាកដមែន។ ជាពិសេសជនជាប់ចោទថែមទាំងបានជេរ ប្រមាថ និងស្រែកគំរាមលើកូនក្តីខ្លួន ដោយមានឈ្មោះ [redacted] ធារ៉ា និងឈ្មោះ [redacted] ហេង គឺជាសាក្សីនៅកន្លែងកើតហេតុ។ ហេតុនេះ ក្នុងនាមជាមេធាវីខ្លួនសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទជាអតិបរមា និងទាមទារសំណងចំនួន៣០,០០០ដុល្លារអាមេរិក តាមការទាមទាររបស់កូនក្តីខ្លួន។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការថា ឆ្លងតាមការសួរដេញដោល និងក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ ចម្លើយសាក្សី និងឯកសារនានាឃើញថាពិតជាមានអង្គហេតុនៃអំពើហិង្សាដោយចេតនា បង្កដោយជនជាប់ចោទឈ្មោះ [redacted] ចិត្រ ប្រព្រឹត្តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ប្រាកដមែន។ ហេតុដូច្នេះសូមលោកចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-ជនជាប់ចោទឈ្មោះ [redacted] ចិត្រ បាននិយាយសម្តីចុងក្រោយថា សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស។

**ផ្អែកតាមកិច្ចពិភាក្សាដេញដោល**

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សម្អាងហេតុ**

**យល់ឃើញថា៖**

១-ពិតជាមានអង្គហេតុនៃអំពើហិង្សាដោយចេតនា បង្កដោយជនជាប់ចោទឈ្មោះ [redacted] ចិត្រ ប្រព្រឹត្តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ប្រាកដមែន។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្រ បញ្ជាក់បានថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៣០នាទី ក្រោយពីខ្លួនបានត្រឡប់មកពីផឹកស្រាសវិញ និងបានជិះម៉ូតូតាមផ្លូវ ខ្លួនបានរោទិ៍ម៉ូតូខ្លាំងៗបង្កជាសំឡេងរំខានដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមហៀប ហើយបានជេរប្រមាថ និងរករឿងវាយគ្នាជាមួយនឹងឈ្មោះ [redacted] គឹមហៀប ថែមទៀតផង។ បន្ទាប់ពីការជេរប្រមាថរួច ខ្លួនបានដើរឆ្លងផ្លូវសំដៅទៅវាយដើមបណ្តឹងរដ្ឋប្បវេណីដល់ខាងមុខផ្ទះតែម្តង ដោយខ្លួនស្ថិតនៅក្នុងស្ថានភាពស្រវឹងមិនអាចទប់ជំហរបាន ក៏ដួលនៅខាងមុខទ្វារផ្ទះរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងប្រគាយប្រតប់ជាមួយដើមបណ្តឹងរដ្ឋ



Scanned with CamScanner

ប្បវេណីបណ្ដាលឱ្យមានរបួសថ្ងាសនៅពេលដែលខ្លួនបានដួលទៅលើផ្លូវដែលមានថ្ម។ ជនជាប់ចោទពិតជាមានចេតនាទុច្ចរិតក្នុងការប្រព្រឹត្តអំពើហិង្សាដោយចេតនាប្រាកដមែន ដោយសារតែខ្លួនបានទៅរករឿងបង្កជម្លោះ និងវាយដើមបណ្ដឹងរដ្ឋប្បវេណីដល់ខាងមុខទ្វារផ្ទះតែម្ដង ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានប្រើប្រាស់សិទ្ធិការពារធម្មានុរូបដើម្បីតបតទៅនឹងសកម្មភាពរបស់ជនជាប់ចោទដែលបានប្រព្រឹត្តមកលើរូបខ្លួនវិញផងដែរ។

៣-ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះឈ្មោះ [redacted] **គីមហៀប** តុលាការជឿថា កាលពីថ្ងៃកើតហេតុជនជាប់ចោទពិតជាបានមកបង្កអំពើហិង្សាដោយចេតនាមកលើជនរងគ្រោះប្រាកដមែន ដោយនៅមុនពេលកើតហេតុគឺដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែអង្គុយលេងនៅខាងក្រោយផ្ទះ ហើយស្រាប់តែជនជាប់ចោទបានជិះម៉ូតូរោទិ៍លាន់លឺសំឡេងខ្លាំងៗ និងបានជេរប្រមាថមកលើជនរងគ្រោះ ទើបជនរងគ្រោះដើរមកខាងមុខផ្ទះ ហើយក៏ត្រូវបានជនជាប់ចោទមកវាយដល់ខាងមុខទ្វារផ្ទះតែម្ដង បណ្ដាលឱ្យមានរបួសដាច់រលាត់ក្បាលជង្គង់ ចំណែកជនជាប់ចោទក៏ត្រូវបានជនរងគ្រោះវាយឱ្យមានរបួសវិញផងដែរ។ សកម្មភាពរបស់ជនរងគ្រោះដែលបានប្រព្រឹត្តទៅលើជនជាប់ចោទគឺដើម្បីការពារខ្លួនពីការបំពារបំពានរបស់ជនជាប់ចោទតែប៉ុណ្ណោះ ហើយដោយសារតែចេតនាទុច្ចរិត និងភាពសាហាវយង់ឃ្នងរបស់ជនជាប់ចោទដែលបានប្រព្រឹត្តទាំងខ្លួនស្ថិតក្នុងស្ថានភាពស្រវឹងជោគជាំ ទើបជនរងគ្រោះប្រើសិទ្ធិការពារខ្លួនវិញ។

៤-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **រីម** និងឈ្មោះ [redacted] **ធឿន** ដែលត្រូវជាឪពុកម្ដាយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិត្រ បញ្ជាក់បានថា នៅថ្ងៃកើតហេតុអ្នកទាំងពីរពិតជាមានវត្តមាននៅកន្លែងកើហេតុ ដោយសារមានផ្ទះទល់មុខនឹងផ្ទះរបស់ជនរងគ្រោះ ហើយកូនប្រុសខ្លួនឈ្មោះ [redacted] ចិត្រ ពិតជាបានជិះម៉ូតូរោទិ៍លឺសូរសំឡេងខ្លាំងបង្កការរំខានដល់ជនរងគ្រោះ ព្រមទាំងបានស្រែកជេរប្រមាថ និងដើរឆ្លងផ្លូវទៅវាយជនរងគ្រោះដល់ខាងមុខទ្វារផ្ទះតែម្ដង ដោយបណ្ដាលឱ្យជនរងគ្រោះមានរបួសជង្គង់ ចំណែកកូនរបស់ខ្លួនវិញមានរបួសថ្ងាសហូរឈាម។ របួសរបស់ជនរងគ្រោះ និងជនជាប់ចោទកើតចេញពីអំពើ និងសកម្មភាពរបស់ជនជាប់ចោទខ្លួនឯងដែលបានបង្កហិង្សាទៅលើជនរងគ្រោះទាំងស្ថិតក្នុងស្ថានភាពស្រវឹង និងបង្កការអុកឡុកនៅក្នុងភូមិ។ ចម្លើយនេះក៏មានភាពស៊ីចង្វាក់ទៅនឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ ឈ្មោះ [redacted] ស្រីម និងឈ្មោះ [redacted] អៀន ដែលជាជីដូនរបស់ជនជាប់ចោទផងដែរគឺសាក្សីក៏មានវត្តមាននៅកន្លែងកើតហេតុ ហើយបានឃើញជនជាប់ចោទទៅវាយជនរងគ្រោះដល់ខាងមុខផ្ទះ ប៉ុន្តែត្រូវជនរងគ្រោះចាប់ក្បាលជាន់ទៅនឹងផ្លូវដែលមានថ្មបណ្ដាលឱ្យមានរបួសបែកថ្ងាសហូរឈាម។

៥-តាមចម្លើយសាក្សីឈ្មោះ [redacted] ធារ៉ា បានបញ្ជាក់ថានៅពេលកើតហេតុខ្លួនបានឃើញជនជាប់ចោទបានមករករឿងជេរប្រមាថ និងបង្កជាអំពើហិង្សាដោយបានវាយទៅលើជនរងគ្រោះឈ្មោះ [redacted] គីមហៀប ជាច្រើនដៃបណ្ដាលឱ្យអុកគូទ និងរងរបួសក្បាលជង្គង់ជាមុននៅខាងមុខទ្វារផ្ទះរបស់ជនរងគ្រោះ ទើបជនរងគ្រោះបានតបតទៅវិញដើម្បីការពារខ្លួន ក៏បានវាយជនជាប់ចោទបណ្ដាលឱ្យមានរបួសបែកថ្ងាសហូរឈាម ហើយត្រូវបានខ្លួន និងសាច់ញាតិរបស់ជនជាប់ចោទចូលមកចាប់បំបែកចេញ។ ទន្ទឹមនឹងនេះ តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ហេង ក៏បានបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនមិនបានឃើញជនរងគ្រោះ និងជនជាប់ចោទប្រតាយប្រតប់ គ្នាទេដោយសារខ្លួននៅខាងក្រោយផ្ទះរបស់ជនរងគ្រោះ ប៉ុន្តែខ្លួនបានលឺសូរសំឡេងរោទិ៍ម៉ូតូខ្លាំងៗ លឺសូរ



Scanned with CamScanner

សំឡេងជេរប្រមាថ និងលឺសូរសំឡេងផ្ទួងផាំងដែលសូរទង្គិចនឹងទ្វារផ្ទះ ហើយក្រោយមកក៏មានក្មេងមកប្រាប់ថា ជនរងគ្រោះ និងជនជាប់ចោទបានប្រតាយប្រតប់គ្នានៅខាងមុខផ្ទះ ទើបខ្លួនបានដើរចេញមកមើល។

៦-តាមរបាយការណ៍សំយោគលេខ៖ ១៥៣/២០២១ រ.ប.ក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពារាំង បានសន្និដ្ឋាន និងវាយតម្លៃថា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៣០នាទី ស្ថិតចំណុចផ្ទះឈ្មោះ [redacted] គីមហៀប ភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង ឈ្មោះ [redacted] ចិត្រ បានមកប្រតាយប្រតប់គ្នាជាមួយឈ្មោះ [redacted] គីមហៀប បណ្តាលឱ្យរងរបួសទាំងសងខាងប្រាកដមែន។

៧-តាមកំណត់ហេតុពិនិត្យស្នាមរបួសលើជនរងគ្រោះឈ្មោះ [redacted] គីមហៀប របស់អធិការដ្ឋាននគរបាលស្រុកពារាំង ជាលទ្ធផលឃើញថា ស្លាកស្នាមចំក្បាលជង្គង់ផ្នែកខាងឆ្វេង និងក្រោមក្បាលជង្គង់បណ្តាលឱ្យធ្លុតស្បែក។ លើឈ្មោះ [redacted] ចិត្រ ជាលទ្ធផលឃើញថា ស្លាកស្នាមរបួសដាច់សាច់ថ្ងាសហើមប៉ោង។ ហេតុដូច្នេះអាចឱ្យតុលាការជឿជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ចិត្រ ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនា ជាបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៨-តាមការពិនិត្យភស្តុតាងដែលអង្គចងចាំ បានបញ្ជាក់ថានៅថ្ងៃកើតហេតុ ជនជាប់ចោទឈ្មោះ [redacted] ចិត្រ ពិតជាបានសំដែងសកម្មភាពច្រឡោងខាម ខឹងសម្បារ និងបានដើរឆ្លងផ្លូវមកវាយជនរងគ្រោះឈ្មោះ ហោ គីមហៀប ដល់ខាងមុខផ្ទះប្រាកដមែន ហើយក៏ត្រូវបានជនរងគ្រោះការពារខ្លួន និងវាយប្រតាយប្រតប់គ្នាបណ្តាលឱ្យរងរបួសបែកថ្ងាសហូរឈាមផងដែរ។

៩-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានមូលដ្ឋានគតិយុត្តដែលអាចឱ្យតុលាការសម្រេចបាន ពីព្រោះតាមចម្លើយសារភាពរបស់ជនជាប់ចោទគឺខ្លួនបានទទួលស្គាល់បទចោទប្រកាន់ ហើយអំពើរបស់ជនជាប់ចោទពិតជាបានបង្កឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានរបួសក្បាលជង្គង់ប្រាកដមែន។ សកម្មភាពរបស់ជនជាប់ចោទត្រូវបានច្បាប់បញ្ញត្តិថាជាបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

១០-តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់គប្បីតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទពីបទ៖ ហិង្សាដោយចេតនា ពីព្រោះតាមចម្លើយសារភាពរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី និងភស្តុតាងជាវីដេអូនៅក្នុងអង្គចងចាំបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើហិង្សាទៅលើជនរងគ្រោះប្រាកដមែន។

១១-តាមសម្តីចុងក្រោយរបស់ជនជាប់ចោទបញ្ជាក់បានថា ជននេះមានស្មារតីភ្ញាក់រលឹកទទួលស្គាល់នូវកំហុសរបស់ខ្លួន ហើយស្តាយក្រោយចំពោះការប្រព្រឹត្តរបស់ខ្លួនទៅលើជនរងគ្រោះ។ ដោយសារជនជាប់ចោទមានចំណេះវិជ្ជាតិចតួច ប្រព្រឹត្តអំពើដោយខ្វះការពិចារណាឱ្យបានល្អិតល្អន់ មានជីវភាពក្រីក្រ ហើយត្រូវមានកូនតូចដែលត្រូវចិញ្ចឹមនៅក្នុងបន្ទុក និងព្យសនកម្មដែលកើតមានចំពោះជនរងគ្រោះមានសភាពតិចតួច។ ហេតុនេះគប្បីតុលាការផ្តល់នូវស្ថានសម្រាលទោសដោយអនុវត្តទោសត្រឹមកម្រិតអប្បបរមានៃទោស។

១២-ពុំមានភស្តុតាងណាមួយមកបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ចិត្រ ថាមានបញ្ហាវិបល្លាសស្មារតី



Scanned with CamScanner

នោះទេ ពោលគឺជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីចំពោះអំពើរបស់ខ្លួន។ អំពើរបស់ជនជាប់ចោទបានស្តែងឡើងនូវចេតនាទុច្ចរិតដែលធ្វើឱ្យប៉ះពាល់ដល់បូរណភាពរូបរាងកាយបុគ្គល សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងច្បាប់ប្រទេស។

១៣-ក្រោយពីបានពិនិត្យពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគីតុលាការប្រកាសថាមានសេចក្តីពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ [redacted] ចិត្រ ពីបទ៖ ហិង្សាដោយចេតនា តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង។

១៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមហៀប បានប្តឹងទាមទារសំណងព្យាបាល និងសំណងជំងឺចិត្រ ចំនួន៣០,០០០ដុល្លារអាមេរិក ពីជនជាប់ចោទ។ ការទាមទារនេះមានមូលដ្ឋានត្រឹមត្រូវ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាខ្លួនបានព្យាបាលរបួសរយៈពេល១សប្តាហ៍ និងចំណាយប្រាក់អស់តែ៥០ដុល្លារអាមេរិកនោះទេ ហើយក៏ពុំមានវិក្កយបត្រមកបញ្ជាក់ពីការចំណាយដែរ។ ហេតុនេះ ការទាមទាមនេះមានចំនួនច្រើនលើសលប់ពីការចំណាយជាក់ស្តែង ដែលតម្រូវឱ្យតុលាការកាត់បន្ថយការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសឈ្មោះ [redacted] ចិត្រ ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ ដែលមានអត្តសញ្ញាណដូចខាងលើដាក់ពន្ធនាគារកំណត់ចំនួន១ (មួយ) ឆ្នាំ ពីបទ៖ **ហិង្សាដោយចេតនា** តាមបញ្ញត្តិមាត្រា**២១៧** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅភូមិល្វាកោង ឃុំកំពង់ប្រាំង ស្រុកពារាំង ខេត្តព្រៃវែង។

២-បង្គាប់ឱ្យឈ្មោះ [redacted] ចិត្រ សងសំណងថ្លៃព្យាបាល និងជំងឺចិត្រជាទឹកប្រាក់ចំនួន៤,០០០,០០០ (**បួនលាន**) **រៀល** ដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គឹមហៀប** តាមបញ្ញត្តិមាត្រា**៣៥៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៤ ខែកុម្ភៈ គ.ស.២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០២ ខែមីនា គ.ស.២០២៣ ចំពោះមុខជនជាប់ចោទ និងចាត់ទុកថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិឧទ្ធរណ៍តាមកំណត់ច្បាប់៕

ថ្ងៃព្រហស្បតិ៍ ១១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ព្រៃវែង, ថ្ងៃទី០២ ខែមីនា គ.ស.២០២៣

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ព្រៃវែង, ថ្ងៃទី០២ ខែមីនា គ.ស.២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]